# សេចក្តីប្រកាសព័ត៌មាន

## វេទិកាស្ថាប័នស្រាវជ្រាវ និងការទូតសាធារណៈកម្ពុជា-ចិន

*ថ្ងៃពុធ ទី១៥ ខែឧសភា ឆ្នាំ២០២៤*
*សណ្ឋាគារ ជ័យ៉ាស្ទីត រាជធានីភ្នំពេញ*

នាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤ វិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI) និងវិទ្យាស្ថាន Charhar បានសហការរៀបចំ **«វេទិកាស្ថាប័នស្រាវជ្រាវ និងការទូតសាធារណៈកម្ពុជា-ចិន»** ក្រោមមូលបទ «ការពង្រឹងកិច្ចសហប្រតិបត្តិការស្ថាប័នស្រាវជ្រាវកម្ពុជា-ចិន ក្នុងការលើកកម្ពស់មិត្តភាព និងកសាងសហគមន៍ជោគវាសនារួម» នៅសណ្ឋាគារជ័យ៉ាស្ទីត រាជធានីភ្នំពេញ។ ពិធីបើកវេទិកានេះប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម **សួស យ៉ារ៉ា** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាននៃរដ្ឋសភាកម្ពុជា ឯកឧត្តម **WANG Wentian** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណៈរដ្ឋប្រជាមានិតចិនប្រចាំនៅកម្ពុជា លោកបណ្ឌិត **HAN Fangming** ប្រធានវិទ្យាស្ថាន Charhar និងជាអនុប្រធានគណៈកម្មាធិការកិច្ចការបរទេសនៃសភាប្រឹក្សានយោបាយប្រជាជនចិន និង លោកបណ្ឌិត **ឆេង គីមឡុង** ប្រធានវិទ្យាស្ថានចក្ខុវិស័យអាស៊ី។ វេទិកានេះក៏មានការចូលរួមពីបញ្ញវន្ត និងអ្នកជំនាញការប្រមាណ ៣០នាក់ មកពីស្ថាប័នស្រាវជ្រាវ និងស្ថាប័នរដ្ឋាភិបាលនៃប្រទេសទាំងពីរ។

នៅក្នុងពិធីបើក លោកបណ្ឌិត **ឆេង គីមឡុង** បានគូសបញ្ជាក់ពីទំនាក់ទំនងដ៏យូរអង្វែង និងអន្តរកម្មរវាងកម្ពុជានិងចិន ដែលបានវិវឌ្ឍន៍ទៅជាមិត្តភាពដែកថែប តាមរយៈការធ្វើឱ្យស៊ីជម្រៅនូវការយល់ពីគ្នាទៅវិញទៅមក និងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យនានា។ លោកបណ្ឌិតក៏បានសង្កតធ្ងន់លើសារៈសំខាន់នៃ «កិច្ចសហប្រតិបត្តិការត្បូងពេជ្រ» ដែលបង្ហាញពីជម្រៅ និងវិសាលភាពនៃទំនាក់ទំនងទ្វេភាគីនៅកម្រិតកាន់តែខ្ពស់។ ក្នុងសុន្ទរកថាបើក ឯកឧត្តម **WANG Wentian** បានសង្កត់ធ្ងន់ថា ទំនាក់ទំនងមិត្តភាពដ៏រឹងមាំរវាងកម្ពុជានិងចិនបាននឹងកំពុងតែរីកចម្រើនឆ្ពោះទៅរកការកសាងសហគមន៍ជោគវាសនារួម។ ឯកឧត្តមបានគូសបញ្ជាក់ថា កិច្ចសហប្រតិបត្តិការស្ថាប័នស្រាវជ្រាវអាចដើរតួនាទីសំខាន់ក្នុងការផ្លាស់ប្តូរវប្បធម៌កម្ពុជា-ចិន និងការស្រាវជ្រាវទ្រឹស្តី ដោយធ្វើជាអ្នកគាំទ្រយ៉ាងខ្ជាប់ខ្ជួន និងអ្នកផ្សព្វផ្សាយសកម្ម នៃការកសាងសហគមន៍ជោគវាសនារួមរវាងប្រជាជាតិទាំងពីរ។ បន្តនៅក្នុងសុន្ទរកថាគន្លឹះ ឯកឧត្តម **សួស យ៉ារ៉ា** បានគូសបញ្ជាក់អំពីការកើនឡើងនូវតួនាទីស្ថាប័នស្រាវជ្រាវ ក្នុងការផ្តល់នូវចំណេះដឹង និងជំនាញដ៏សម្បូរបែប ដើម្បីរៀបចំយុទ្ធសាស្ត្រការទូតសាធារណៈប្រកបដោយប្រសិទ្ធភាព។ ឯកឧត្តមក៏បានកត់សម្គាល់ផងដែរថា វិធានការនេះមានការពាក់ព័ន្ធនឹងការស្វែងយល់ពីអភិក្រមប្រកបដោយនវានុវត្ត ការផ្លាស់ប្តូរការឧត្តមានុវត្ត និងការជំរុញកិច្ចសហ

ប្រតិបត្តិការឱ្យកាន់តែស៊ីជម្រៅរវាងស្ថាប័នស្រាវជ្រាវ ដែលនឹងហុចផលដល់ការពង្រឹងទំនាក់ទំនងប្រទេសទាំងពីរ។

ឆ្លៀតក្នុងឱកាសនោះ វិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI) និងវិទ្យាស្ថាន Charhar បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នា (MoU) ដែលសំដៅពង្រឹងទំនាក់ទំនងមិត្តភាពរវាងស្ថាប័នស្រាវជ្រាវទាំងពីរ និងសម្របសម្រួលការផ្លាស់ប្តូរដ៏រស់រវើក ជំរុញកម្រិតនៃកិច្ចសហការឱ្យកាន់តែស៊ីជម្រៅ និងការចែករំលែកចំណេះដឹងរវាងស្ថាប័ននៃប្រទេសទាំងពីរ។

កម្មវិធីនេះបានបន្តដោយមានការធ្វើបទបង្ហាញ និងវគ្គពិភាក្សា លើប្រធានបទជាច្រើន ដែលភាគច្រើនផ្តោតលើកិច្ចសហប្រតិបត្តិការស្ថាប័នស្រាវជ្រាវក្នុងការទូតសាធារណៈរវាងកម្ពុជានិងចិន និង តួនាទីនៃស្ថាប័នស្រាវជ្រាវដែលតម្រង់ទិសសកម្មភាពក្នុងការបម្រើដល់ក្របខណ្ឌកិច្ចសហប្រតិបត្តិការត្បូងពេជ្រ។ បន្ទាប់ពីកិច្ចពិភាក្សាជាលក្ខណៈបើកចំហរ បញ្ញវន្ត និងអ្នកជំនាញបានឯកភាពគ្នាយ៉ាងទូលំទូលាយលើចំណុចដូចជា៖ (១) កិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា-ចិន មានប្រវត្តិយូរអង្វែង និងមានមូលដ្ឋានគ្រឹះច្បាស់លាស់ (២) ស្ថាប័នស្រាវជ្រាវដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចសហប្រតិបត្តិការទ្វេភាគី ដោយមិនត្រឹមតែដោះស្រាយបញ្ហាជាក់ស្តែងនៃកិច្ចសហប្រតិបត្តិការនាពេលបច្ចុប្បន្នប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពិនិត្យមើលលើទំនាក់ទំនងកម្ពុជា-ចិនក្នុងរយៈពេលវែងនាពេលអនាគត ដែលមានភាពស៊ីជម្រៅនិងរឹងមាំ និង (៣) ការទូតសាធារណៈ គឺជាកត្តាសំខាន់ក្នុងការផ្សារភ្ជាប់ និងជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីសម្រាប់ការអភិវឌ្ឍនាពេលអនាគត។

វិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI) និងវិទ្យាស្ថាន Charhar នឹងចេញផ្សាយនូវរបាយការណ៍រួមមួយដែលមានចំណងជើងថា «ស្ថាប័នស្រាវជ្រាវ និងការទូតសាធារណៈកម្ពុជា-ចិន៖ ការអភិវឌ្ឍ និងទស្សនវិស័យ» ដោយរួមបញ្ចូលនូវទស្សនៈទាំងអស់ដែលបានពិភាក្សាក្នុងវេទិកាខាងលើ និងស្វែងរកធាតុចូលបន្ថែមទៀតពីបញ្ញវន្តមកពីស្ថាប័នទាំងពីរ។ របាយការណ៍នេះនឹងបម្រើជាឯកសារសំខាន់ ដោយផ្តល់នូវអនុសាសន៍គោលនយោបាយ ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យការទូតសាធារណៈ និងកំណត់លក្ខណៈនៃភាពបើកចំហរ ភាពចម្រុះ និងចំណុចប្រសព្វនៃកិច្ចសហប្រតិបត្តិការទ្វេភាគី។ ជាចុងក្រោយ ភាគីទាំងពីរបានសម្តែងការប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លាក្នុងការរួមគ្នាអនុវត្តការកសាងសមត្ថភាព បង្កើតឱកាសសម្រាប់ការផ្លាស់ប្តូរគំនិត និងធ្វើឱ្យស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូលើការស្រាវជ្រាវជាក់ស្តែងនាពេលអនាគត។

ថ្ងៃសៅរ៍ ១១កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៤

**វិទ្យាស្ថានចក្ខុវិស័យអាស៊ី**